# សេចក្តីជូនដំណឹង
# ស្តីពី
# ការជ្រើសរើសបុគ្គលិក
# ទទួលបន្ទុកការងារលេខាធិការដ្ឋានថ្នាក់ខេត្ត-តំបន់ និងជំនួយការការិយាល័យ

សហព័ន្ធស្រូវអង្ករកម្ពុជា(ស.អ.ក) ជាស្ថាប័នមិនរកប្រាក់ចំណេញឈានមុខមួយក្នុងវិស័យឯកជនដោយមានកាតព្វកិច្ចចម្បងក្នុងការជំរុញ និងពង្រឹងគ្រប់ភាគីពាក់ព័ន្ធសំខាន់ៗក្នុងខ្សែចង្វាក់វិស័យស្រូវអង្ករ ជាពិសេសកសិករ សហគមន៍កសិកម្ម ម្ចាស់រោងម៉ាស៊ីនកិនស្រូវ និងក្រុមហ៊ុននាំចេញអង្ករ ដោយបានទទួលស្គាល់ដោយអនុក្រឹត្យលេខ ២២៤ អនក្រ.បក ចុះថ្ងៃទី០៨ ខែសីហា ឆ្នាំ២០១៤ ដោយរាជរដ្ឋាភិបាល។

ដើម្បីឆ្លើយតបទៅនឹងការអនុវត្តនូវផែនការយុទ្ធសាស្រ្ត និងផែនការសកម្មភាពរយៈពេល៥ឆ្នាំរបស់សហព័ន្ធស្រូវអង្ករកម្ពុជា ក៏ដូចជាជួយគាំទ្រដល់តួនាទីសេដ្ឋកិច្ចនិងសង្គមជាតិព្រមទាំងគោលនយោបាយរបស់រាជរដ្ឋាភិបាល សហព័ន្ធស្រូវអង្ករកម្ពុជាត្រូវការជ្រើសរើសអ្នកដែលមានជំនាញនិងបទពិសោធខ្ពស់ដើម្បីជួយសម្របសម្រួល និងអនុវត្តការតាមផែនការ។ បេក្ខជនគួរមានការយល់ដឹងខ្ពស់អំពីបច្ចេកទេសអំពីបញ្ហាប្រឈមទាំងឡាយក្នុងវិស័យស្រូវអង្ករ និងយល់ច្បាស់ពីកាតព្វកិច្ចដែលជាបន្ទុកចំពោះមុខរបស់ខ្លួន។បេក្ខជនត្រូវមានបទពិសោធន៍ក្នុងការដឹកនាំនិងគ្រប់គ្រងក្នុងការផ្តួចផ្តើមរៀបចំការងារបន្តដោយជោគជ័យ ហើយត្រូវជាបុគ្គលដែលមានសមត្ថភាពដឹកនាំ មានបុគ្គលិកលក្ខណៈនិងមានជំនាញក្នុងការធ្វើទំនាក់ទំនងល្អព្រមទាំងមានឆន្ទៈខ្ពស់ក្នុងការធ្វើការងារជាក្រុម។ បេក្ខជនគួរជាអ្នកដែលមានសមត្ថភាពដោះស្រាយបញ្ហាខ្ពស់បំផុត ប្រកបដោយជំនាញក្នុងការវិភាគនិងភាពជាអ្នកដឹកនាំ។ ភាពស្ទាត់ជំនាញក្នុងការប្រើប្រាស់ភាសាខ្មែរនិងអង់គ្លេស។

**ការជ្រើសរើសតាមផ្នែកមានដូចខាងក្រោម៖**

## ១ .បុគ្គលិកតំណាងចំនួន ២រូប ប្រចាំតំបន់ទី២ និងទី៣

តំណាងសហព័ន្ធប្រចាំតំបន់នីមួយៗ មានភារកិច្ចជាលេខាធិការក្រុមការងារថ្នាក់ខេត្ត-តំបន់ និងសម្របសម្រួលជាមួយសមាជិកនៅមូលដ្ឋាន មានដូចជា៖ រោងម៉ាស៊ីន សហគមន៍កសិកម្ម ក្រុមហ៊ុន ផលិតពូជស្រូវ។ល។ ដើម្បីប្រមូលនូវបញ្ហានានា ដាក់ជូនតំណាងក្រុមការងារថ្នាក់ខេត្ត-តំបន់ ដើម្បីស្នើបញ្ចូលក្នុងកិច្ចប្រជុំដោះស្រាយបញ្ហាជាមួយភាគីពាក់ព័ន្ធនៅថ្នាក់ខេត្ត-តំបន់ ឬរាយការណ៍មកសាខាសហព័ន្ធ នូវបញ្ហាទាំងឡាយដែលប៉ះដល់រោងម៉ាស៊ីន ជីវភាពរបស់កសិករ សហគមន៍កសិកម្ម ការដាំដុះស្រូវ រួមមាន ពូជស្រូវ ជីថ្នាំ ការបង្កើនទិន្នផល ស្តង់ដាបច្ចេកទេសនិងបច្ចេកវិទ្យាក្នុងការដាំដុះ ប្រព័ន្ធធារាសាស្រ្ត និងទីផ្សារជាដើម។ ហើយត្រូវអនុវត្តនូវផែនការយុទ្ធសាស្រ្ត និងផែនការសកម្មភាពរបស់សហព័ន្ធ ដើម្បីជម្រុញការបង្កើនការផលិត និងភាពប្រកួតប្រជែងរបស់រោងម៉ាស៊ីន និងកសិករទូទៅ ព្រមទាំងពង្រីកទីផ្សារស្រូវនិងពូជរបស់កសិករ។ ការងារទាំងនេះទាមទារការចុះអនុវត្តការងារដោយផ្ទាល់តាមបណ្តាខេត្ត ហើយដើរតួនាទីជាអន្តរបុគ្គលរបស់សហព័ន្ធ ជាមួយនឹងតំណាងរោងម៉ាស៊ីន តំណាងសហគមន៍កសិកម្ម ក៏ដូចជាស្ថាប័នរដ្ឋ និងអង្គការពាក់ព័ន្ធនានា។

<u>លក្ខខណ្ឌសមត្ថភាព និងចំណេះដឹង៖</u>

- មានសញ្ញាបត្រចាប់ពីថ្នាក់បរិញ្ញាបត្រ ឬវិញ្ញាបនបត្រមានតម្លៃស្មើ ផ្នែកកសិកម្ម
- មានបទពិសោធន៍ចាប់ពី ០២ឆ្នាំ ឡើងទៅក្នុងការងារគ្រប់គ្រងនិងដឹកនាំការងារក្នុងវិស័យកសិកម្មជាពិសេសដំណាំស្រូវ ការងារជាមួយរោងម៉ាស៊ីន សហគមន៍កសិករនិងផលិតកម្មពូជស្រូវជាដើម។
- មានយល់ដឹងខ្ពស់ពីវិស័យស្រូវអង្ករ និងចេះប្រើប្រាស់កំព្យូទ័រ Word-Excel-Power Point ជាដើម
- មានអាយុចាប់ពី ២៥ឆ្នាំ ឡើងទៅ
- មានភាពរួសរាយទាក់ទាក់ និងមានទំនាក់ទំនងការងារល្អ
- ឧស្សាហ៍ព្យាយាម ស្មោះត្រង់ និងការទទួលខុសត្រូវខ្ពស់ក្នុងការងារ
- មានសមត្ថភាពធ្វើការងារជាក្រុម ។

## ២. បុគ្គលិកផ្នែកជំនួយការការិយាល័យ ចំនួន ០១ រូប

<u>លក្ខខណ្ឌសមត្ថភាព និងចំណេះដឹង៖</u>

- បុគ្គលិកទាំងពីរភេទ ត្រូវមានអាយុចាប់ ២១ឆ្នាំ ដល់ ៣០ឆ្នាំ
- បញ្ចប់ថ្នាក់បរិញ្ញាបត្រ ឬសញ្ញាបត្រដែលមានតម្លៃស្មើ
- ត្រូវមានជំនាញ និងបទពិសោធន៍ការងារការិយាល័យ
- មានចំណេះដឹងផ្នែកភាសាអង់គ្លេស និងជំនាញកំព្យូទ័រ Word-Excel-Power Point
- មានភាពរួសរាយ រាក់ទាក់ និងមានទំនាក់ទំនងការងារល្អ
- មានអត្តចរិកស្លូតបូត សុភាពរាបសា និងមានកាយសម្បទាមាំមួន
- ឧស្សាហ៍ព្យាយាម ស្មោះត្រង់ និងការទទួលខុសត្រូវខ្ពស់ក្នុងការងារ

បេក្ខជន បេក្ខនារី ដែលមានចំណាប់អារម្មណ៍ សូមផ្ញើប្រវត្តិរូប (CV) និងអត្តសញ្ញាប័ណ្ណ មកកាន់អាសយដ្ឋាន និងអ៊ីម៉ែលដូចមានខាងក្រោម៖

**ផុតកំណត់** ៖ **ថ្ងៃទី២០ ខែមិនា ឆ្នាំ២០១៧**

**ទំនាក់ទំនង** ៖ លោក ភុន ខេមរា មន្ត្រីផ្នែកធនធានមនុស្ស

**អ៊ីមែល** ៖ info@crf.org.kh /phunkhemra168@gmail.com

**ទូរស័ព្ទ** ៖ **០៩២-៧២២ ៧៩៧ / ០៩៨ ៩០០ ៣០០**

**អាសយដ្ឋាន** ៖ អគារពាណិជ្ជកម្មសូម៉ាលេខ២២C ជាន់ទី៧ ផ្លូវលេខ១១២០ សង្កាត់ផ្សារថ្មីII ខណ្ឌដូនពេញ រាជធានីភ្នំពេញ។